# គណបក្ស សិទ្ធិមនុស្ស
# HUMAN RIGHTS PARTY

បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី៣ ខែមេសា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ០៧៩ ឆ្នាំទី២*


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅខេត្តកណ្តាល | ១ |
| -រដ្ឋាភិបាលទាត់ចោលនូវរបាយការណ៍មួយរបស់ទស្សនាវដ្តី Forbes ស្តីពីបញ្ហាពុករលួយនៅកម្ពុជា | ២ |
| -កម្មករប្រមាណជាង១០០០នាក់នឹងមិនមានប្រាក់សម្រាប់ចូលរួមអបអរសាទរឆ្នាំថ្មី | ៣ |
| -លិខិតរំលែកទុក្ខ | ៣ |

## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅខេត្តកណ្តាល

ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស បានចុះទៅសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងសកម្មជនគណបក្សសិទ្ធិមនុស្ស នៅភូមព្រៃក ជ្រូក ឃុំព្រៃកគយ ស្រុកស្អាង ខេត្តកណ្តាល កាលពីព្រឹកថ្ងៃ ទី២៨ ខែមីនា ឆ្នាំ២០០៩ ។

លោក **ប៉ែន សុវណ្ណ** បានបន្តទៀតថានៅឆ្នាំនេះប្រជាពលរដ្ឋនៅឃុំព្រៃកគយ រកត្រីប្រកបរបរធ្វើផ្អកគ្មានទេ មូលហេតុនេះដោយសារ អាជ្ញាធរបំផ្លិចបំផ្លាញធម្មជាតិហើយ ធ្វើឱ្យខ្មែរកាន់តែវេទនាក្រីក្រ ហើយប្រជាពលរដ្ឋដែលមានដីធ្លីបន្តិចបន្តួចត្រូវបានមានអំណាចរឹបអូសរំលោភបំពានយកដីធ្លី ។

តំណាងគណបក្សសិទ្ធិមនុស្ស ប្រចាំឃុំព្រៃកគយ ស្រុកស្អាងបាននិយាយថា ប្រជាពលរដ្ឋនៅក្នុងឃុំព្រៃកគយ បានគាំទ្រគណបក្សសិទ្ធិមនុស្ស ដោយសារលោកមើលឃើញគោលការណ៍គណបក្សល្អ ព្រមទាំងអាចដឹកនាំប្រទេសជាតិ ឱ្យមានការរីកចំរើនធ្វើឱ្យប្រជាពលរដ្ឋមានសិទ្ធិសេរីភាព ។ ម្យ៉ាងទៀតគោលការណ៍គណបក្សសិទ្ធិមនុស្ស ជួយប្រជាពលរដ្ឋឱ្យមានការជីវភាពធូរធារជួយចាស់ជរាឱ្យមានប្រាក់ឧបត្ថម្ភ និងដោះស្រាយបញ្ហាបូរណភាពទឹកដី និងជនអន្តោប្រវេសន៍ដំយួរ ។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស បានថ្លែងទៅកាន់ប្រជាពលរដ្ឋ ដែលចូលរួមក្នុងពិធីសំណេះសំណាលថាសន្តិភាពបានមកពីមនុស្សទាំងអស់គ្នា ហើយកាលណាមានសិទ្ធិមនុស្សទើបមានប្រជាធិបតេយ្យ ប៉ុន្តែបើអត់មានប្រជាធិបតេយ្យ ក៏គ្មានយុត្តិធម៌ដែរ ។ លោក **កឹម សុខា** បានបន្តទៀតថាដើម្បីឱ្យមានសន្តិភាពទាល់តែមានយុត្តិធម៌ ដើម្បីឱ្យមានយុត្តិធម៌ ទាស់តែមានប្រជាធិបតេយ្យ ដើម្បីឱ្យមានប្រជាធិបតេយ្យទាល់តែការគោរព

សិទ្ធិមនុស្ស ។ ដូច្នេះហើយបានថា គណបក្សសិទ្ធិមនុស្ស ផ្តោតសំខាន់ទៅលើការគោរពសិទ្ធិមនុស្សដើម្បីឱ្យមានសន្តិភាព ។

## រដ្ឋាភិបាលទាត់ចោលនូវរបាយការណ៍មួយរបស់ទស្សនាវដ្តី Forbes ស្តីពីបញ្ហាពុករលួយនៅកម្ពុជា

ប្រទេសកម្ពុជា ជាប់ចំណាត់កំពូលពុករលួយ ទាំង១០នៅលើពិភពលោក បើយោងតាមការចុះផ្សាយរបស់កាសែត The Cambodia Daily ដែលបានចេញផ្សាយនៅថ្ងៃទី២៦ ខែមីនា នេះកាសែត The Cambodia Daily បានដកស្រង់អត្ថបទចេញផ្សាយដោយទស្សនាវដ្តី Forbes ផ្សាយកាលពី ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ដែលជាទស្សនាវដ្តី ដែលមានឥទ្ធិពលមួយបានចេញផ្សាយឱ្យដឹងថាប្រទេសកម្ពុជា ជាប្រទេសមួយជាប់ចំណាត់ថ្នាក់ពុករលួយ ក្នុងចំណោមប្រទេសកំពូលពុករលួយ១០ នៅលើពិភពលោក ។

ពតិមានអាស្រូវជាងនេះទៅទៀត ពីក្រុមអ្នកវិភាគសេដ្ឋកិច្ចបានចាត់ទុកថា ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពដែលអាចកើតមានអស្ថេរភាពដ៏ខ្ពស់ ដោយហេតុនៃវិបត្តិសេដ្ឋកិច្ចពិភពលោក ។

Forbes ដែលបានដាក់កម្ពុជាកំពូលសែនពុករលួយទាំង១០នេះបានបញ្ជាក់ថា ប្រាក់ដែលអង្គការសហប្រជាជាតិដែលបានដាក់ចូលទៅក្នុងថវិកា សំរាប់ការកាត់ក្តីខ្មែរក្រហមបានត្រូវលួចដោយមន្ត្រីរដ្ឋាភិបាល ។ Forbes សរសេរទៀតថាថវិកាដែលបានខិតខំរកចំនួន១៣ឆ្នាំសំរាប់ការកាត់ទោសបានត្រូវអស់មុនការកាត់ទោសចាប់ផ្តើម ។

លោក **ជាម យៀប** សមាជិករដ្ឋសភា មកពីគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍ថា អំពើពុករលួយនេះកំពុងជាបញ្ហាមួយ ប៉ុន្តែលោកមិនទទួលយករបាយការណ៍របស់ទស្សនាវដ្តី Forbes នោះទេ ។ លោកមានប្រសាសន៍ ទៀតថាលោកមិនដឹងថាតើ Forbes សំខាន់ទៅលើអ្វីឡើយដើម្បីចេញរបាយការណ៍នេះ ។ អំពើពុករលួយនៅក្នុងប្រទេសកម្ពុជាកើតឡើងដោយសារបញ្ហាជីវភាព អំពើលោភលន់ និងការស្រលាញ់អំណាច ។

លោក **ជាម យៀប** បានបន្ថែមថា រដ្ឋាភិបាលបានធ្វើអ្វីគ្រប់យ៉ាងដើម្បីកាត់បន្ថយអំពើពុករលួយ ដែលបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៩ បាននឹងកំពុងស្ថិតរង្វង់ដៃនៃគណៈកម្មការអន្តរក្រសួង ។ ច្បាប់នេះត្រូវផ្ញើរទៅទីស្តីការគណៈរដ្ឋមន្ត្រីមុននឹងដល់សភាជាតិ ប៉ុន្តែលោកក៏មិនបានផ្តល់នូវកាលបរិច្ឆេទពិតប្រាកដ នូវច្បាប់ដែលបានពន្យារដ៏យូរលង់នេះថា ចេញប្រើនៅថ្ងៃណាទេ ។

ចំណែកឯលោក **វ៉ុង ឈុន** បានមានប្រសាសន៍ ថាច្បាប់ប្រឆាំងអំពើពុករលួយបានព្រាងតាំងពីឆ្នាំ១៩៩៤មកម្លេះរហូតមកដល់ ពេលនេះមិនដឹងថារត់ច្បាប់នេះទៅដល់ណាហើយទេ ។

ទាក់ទិននឹងបញ្ហានេះ លោក **ឱម យិនទៀង** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយផងនោះមាន ប្រសាសន៍ថាច្បាប់ប្រឆាំងអំពើពុករលួយនឹងឆាប់ចេញប្រើមិនយូរទៀតទេប៉ុន្តែលោកមិនបានបញ្ជាក់ឱ្យច្បាស់ថា តើច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងចេញនៅពេលណាទេ ។

លោក **គឹម សុខា** សមាជិកសភាតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ថា ជាការពិតទាំងប្រជាពលរដ្ឋខ្មែរ និងអង្គការសង្គមស៊ីវិលក្នុងស្រុកមើលឃើញថា អំពើពុករលួយមានសភាពធ្ងន់ធ្ងរណាស់ មានលក្ខណៈជាប្រព័ន្ធ ហើយមិនមែនពុករលួយដោយចៃដន្យមួយពីរនោះទេ ។ ពោលគឺកើតឡើងពីលើទៅក្រោម ពីក្រោមទៅលើ ហើយកើតមាននៅគ្រប់ទិសទីទាំងអស់តែរដ្ឋាភិបាលមិនមានយន្តការដើម្បីទប់ស្កាត់ឱ្យមានប្រសិទ្ធភាព ។

លោក **គឹម សុខា** អតីតសមាជិកព្រឹទ្ធសភាបច្ចុប្បន្នអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមរូបនេះ បានគូសបញ្ជាក់បន្ថែមថា បញ្ហាអំពើពុករលួយនេះ គឺជារឿងរបស់យើងទាំងអស់

គ្នា ទាំងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង ត្រូវតែរួមគ្នាដោះស្រាយ ពីព្រោះអំពើពុករលួយនេះធ្វើឱ្យប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋ និងប៉ះពាល់ដល់ជីភាពប្រជាពលរដ្ឋ ហើយក៏ប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ ។ ដូច្នេះគណបក្សទាំងអស់នៅក្នុងសភាគួរតែជជែកគ្នាដើម្បីឱ្យច្បាប់ប្រឆាំង អំពើពុករលួយចេញ បន្ទាប់មកទើបយើងប្រើយន្តការអនុវត្តន៍ច្បាប់នេះឱ្យមានប្រសិទ្ធភាព ។

សូមជំរាបថា កាលពីចុងខែកញ្ញា ឆ្នាំ២០០៨កន្លងមក អង្គការតម្លាភាពអន្តរជាតិបានទំលាយរបាយការណ៍អាស្រូវ ស្ដីពីកម្ពុជាទាក់ទងនឹងអំពើពុករលួយ ដោយក្នុងរបាយការណ៍បាននិយាយថាប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ១៦៦ក្នុងចំណោមប្រទេស១៨០លើពិភពលោកដែលពុករលួយ ។

## កម្មករប្រមាណជាង១០០០នាក់នឹងមិនមានប្រាក់សម្រាប់ចូលរួមអបអរសាទរឆ្នាំថ្មី

កម្មករប្រមាណ២៤០នាក់នៅរោងចក្រ **អ៊ីណេស** Garment ស្ថិតក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញបានធ្វើកូដកម្មប្រឆាំងនឹងថៅកែរោងចក្រ ដែលមិនបានបើកប្រាក់ខែឱ្យកម្មករ និងកំលាំងសន្តិសុខ បានបើករថយន្តបំបុកប្រធានសហជីព ខណៈពេលដែលកម្មកររាំងខ្ទប់មិនឱ្យរថយន្តដឹកទំនិញចេញក្រៅ ។

លោក **ប៉ុល ផាន់មឿង** ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា បានថ្លែងថាមានកម្មករចំនួន២៤០នាក់ បានទាមទារឱ្យថៅកែរោងចក្របើកប្រាក់ខែ គឺខែកុម្ភៈ តែរហូតមកដល់ថ្ងៃទី២៦ ខែមីនានេះ ខាងភាគីខាងរោងចក្រមិនទាន់បើកប្រាក់ខែឱ្យកម្មករនៅឡើយទេ ដែលយ៉ាងហោចណាស់ក៏កម្មករម្នាក់ទទួលបានប្រាក់ឈ្នួល៤០ដុល្លារ ក្នុង១ខែ ។

លោក **ថៃ បញ្ញា** យុវកម្មករម្នាក់បាននិយាយថាការធ្វើកូដកម្មនៅថ្ងៃនេះ ដើម្បីតវ៉ាឱ្យទៅរោងចក្របើកប្រាក់ខែឱ្យពួកគេ ហើយប្រាក់ខែរបស់យុវកម្មករូបនោះទទួលបាន៦០ដុល្លារប៉ុណ្ណោះ។

លោក **ថៃ បញ្ញា** បាននិយាយទៀតថាកំលាំងសន្តិសុខដោយមានការការពារពីកងកំលាំងប្រដាប់អាវុធផងនោះ បានបើករថយន្តបុកកម្មករ ។ មិនត្រឹមតែប៉ុណ្ណោះរោងចក្របានរកលេសឱ្យកម្មករដាក់លិខិតលាលែងលើការងារ ដើម្បីមិនបើកប្រាក់ខែឱ្យកម្មករ ។

លោក **កុយ ទេពតារារ៉ុត** ប្រធាននាយកដ្ឋានវិវាទការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឆ្លើយថា លោកមិនទាន់បានទទួលពតិមានកូដកម្មនៅរោងចក្រ **អ៊ីណេស** មិននៅឡើយទេបើទោះបីជាកម្មករនៅទីនោះអះអាងថាមន្ត្រីក្រសួងការងារ បានចុះទៅពិនិត្យមើល ប៉ុន្តែក្រោយមកមន្ត្រីក្រសួងការងារ បែរជាចាកចេញបន្ទាប់ពីឃើញស្ថានការណ៍មិនសូវស្រួល ។

លោក **លី ផាំ** ប្រធានចលនាកម្មកររបស់គណបក្សសិទ្ធិមនុស្ស គួសបញ្ជាក់ថា ករណីរោងចក្រមិនបើកប្រាក់ខែឱ្យកម្មករ គឺជាទង្វើរំលោភសិទ្ធិកម្មករការធ្វើកូដកម្ម និងជារឿងធម្មតា ហើយបើក្រុមហ៊ុនមិនព្រមដោះស្រាយបញ្ហាឱ្យកម្មករៗត្រូវតែធ្វើកូដកម្ម ហើយនេះមិនមែនជារឿងហួសហេតុនោះទេ ។ សំខាន់និយោជកត្រូវតែចេះដោះស្រាយដើម្បកាត់បន្ថយជំលោះរវាងកម្មករ និងថៅកែរោងចក្រ ។

## លិខិតចូលរួមរំលែកមរណទុក្ខលោកស្រីភរិយាសពលោក ស៊ឹម ឈេត និងក្រុមគ្រួសារ

ក្នុងនាមថ្នាក់ដឹកនាំសមាជិក សមាជិការបស់ **គណបក្សសិទ្ធិមនុស្ស** ទាំងក្នុង និងក្រៅប្រទេស និង ក្នុងនាមខ្ញុំផ្ទាល់ យើងខ្ញុំទាំងអស់មានសេចក្ដីទុក្ខសោកក្រៀមក្រំ យ៉ាងខ្លាំងក្រោយ

ពីបានទទួលពតិមានថា លោក **ស៊ឹម ណេត** ជាសកម្មជនដ៏ឆ្នើមរបស់គណបក្សសិទ្ធិមនុស្សបានទទួលមរណភាព ដោយការបាញ់ប្រហារពីក្រុមឃាតករដ៏ ឃោរឃៅកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ នៅវេលាម៉ោងប្រមាណ១២យប់ ខណៈដែលគាត់កំពុងជិះម៉ូតូនៅតាមដងផ្លូវត្រឡប់ទៅផ្ទះវិញ ។

មរណភាពរបស់លោក **ស៊ឹម ណេត** គឺជាការបាត់បង់ស្វាមី ឪពុក បងប្អូនដ៏ឧត្តមនៃក្រុមគ្រួសារលោក ស្រីក៏ដូចជាគណបក្សសិទ្ធិមនុស្សទាំងមូល ។

### គ្រួសារសពជាទីគោរព !

**គណបក្សសិទ្ធិមនុស្ស** ចាត់ទុករូបលោក **ស៊ឹម ណេត** ជាសមាជិកសកម្មដ៏ឆ្នើម អង់អាច ក្លាហាន និងស្មោះត្រង់ចំពោះជាតិ មាតុភូមិ ដែលរូបខ្ញុំក្តី សមាជិកឯទៀតក្តីចងចាំនូវគុណូបការៈរបស់លោក ហើយប្តេជ្ញាបន្តការតស៊ូដើម្បីសេរីភាព និងលទ្ធិប្រជាធិបតេយ្យដែលជាក្តីប្រាថ្នារបស់លោកឱ្យបានសំរេច ។ យើងខ្ញុំសូមបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់លោក **ស៊ឹម ណេត** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកស្រី បុត្រ និងក្រុមគ្រួសារលោក **ស៊ឹម ណេត** ទាំងអស់មេត្តាទទួលនូវការគោរព និងការរំលែកទុក្ខអំពីយើងខ្ញុំទាំងអស់គ្នា ។

## សេចក្តីថ្លែងការណ៍

**គណបក្សសិទ្ធិមនុស្ស** មានសេចក្តីក្រៀមក្រំយ៉ាងខ្លាំងក្រោយពីបានទទួលពតិមានថាលោក **ស៊ឹម ណេត** អាយុ៤៨ឆ្នាំ ដែលជាសកម្មជនដ៏មានប្រជាប្រិយរបស់គណបក្សសិទ្ធិមនុស្សនៅឃុំកណ្តួរជ្រៃ ស្រុកពញាក្រែក ខេត្តកំពង់ចាម បានត្រូវឃាតករបាញ់សំលាប់យ៉ាងឃោរឃៅទៅលើរូបលោក កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោងប្រមាណ១២យប់ ខណៈដែលគាត់កំពុងជិះម៉ូតូតាមដងផ្លូវធ្វើដំណើរទៅផ្ទះគាត់ ។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា នេះជាអំពើឃាតកម្មយ៉ាងសាហាវ ព្រៃផ្សៃដែលបានរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសន្តិសុខផ្ទាល់ខ្លួនរបស់បុគ្គល និងសិទ្ធិនយោបាយរបស់លោក **ស៊ឹម ណេត** ។ មិនតែប៉ុណ្ណោះឃាតកម្មនេះបានបង្កឱ្យមានការភ័យខ្លាចនៅក្នុងអារម្មណ៍សកម្មជននយោបាយក៏ ដូចជាប្រជាពលរដ្ឋខ្មែរទូទៅផងដែរ ។

**គណបក្សសិទ្ធិមនុស្ស** ថ្កោលទោសយ៉ាងខ្លាំងចំពោះក្រុមឃាតករ និងអ្នកសមគំនិត និងសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ច ស្វែងរកចាប់ឃាតករពិតឱ្យបានដើម្បីផ្តន្ទាទោសរកយុត្តិធម៌ជូនជនរងគ្រោះ និងគ្រួសារព្រមទាំងបំបាត់ចោលឱ្យអស់នូវទម្រង់និទណ្ឌភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨,សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |

**វិបត្តិសេដ្ឋកិច្ចពិភពលោកធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់វិស័យឧស្សាហកម្មនៅកម្ពុជា !**